ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Mar-2015, 14:51
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** អមដោយ ឧបសម្ពន្ធ**សម្ងាត់បំផុត** ពីរ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការដាក់បញ្ចូលរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤-D193/16**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន
**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSÉ
**មេធាវីប្រចាំការ:**
លោកស្រី ទូច វលក្ស
លោក Calvin SAUNDERS
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

## I. ការដាក់បង្ហាញ

១. សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") សូមដាក់បង្ហាញកំណត់ហេតុលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរចំនួនមួយ ("ឯកសារ") ដែលបានទទួលយកក្នុងសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង០០២/០២។ ឯកសារនេះត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុង **ឧបសម្ព័ន្ធ ៣**។ ឯកសារនេះកំពុងត្រូវបានដាក់បង្ហាញជាសំណៅកោសលុប ពីសំណាក់សហចៅក្រមស៊ើបអង្កេត អន្តរជាតិ ថាជា **ឧបសម្ព័ន្ធ ១** សម្ងាត់បំផុត។

២. សហព្រះរាជអាជ្ញា បានស្វែងរកការអនុញ្ញាតដាក់បង្ហាញឯកសារនេះ តាមរយៈសំណើមួយដែលបានដាក់ទៅសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៥[1]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយល់ព្រមតាមសំណើសុំដែលពាក់ព័ន្ធទៅនឹងឯកសារនេះ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ដែលសេចក្តីសម្រេចនោះត្រូវបានគេចែកជូនទៅអង្គជំនុំជម្រះសាលាដំបូង[2]។

៣. អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា កាតព្វកិច្ចក្នុងការដាក់បង្ហាញសម្ភារៈពាក់ព័ន្ធ ទោះជាដាក់បន្ទុក ឬដោះបន្ទុកក្តី គឺជាកាតព្វកិច្ចដែលអង្គជំនុំជម្រះមាន ក៏ដូចជាជនជាប់ចោទដែរ ដោយហេតុថា "ជាប្រយោជន៍ដែលនាំដល់ការស្វែងរកការពិត ដែលអង្គជំនុំជម្រះមានសិទ្ធិចូលពិនិត្យមើលឯកសារទាំងនេះ"[3]។ ជាងនេះទៀត អង្គជំនុំជម្រះធ្លាប់បានសម្រេចពីមុនថា "វិធាន៥៣(៤) នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចជាបន្តបន្ទាប់ទៅលើសហព្រះរាជអាជ្ញា ក្នុងការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង នូវឯកសារណាដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ដែលអាចជានត្ថិភាពនៃពិរុទ្ធ ឬសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬអាចមានឥទ្ធិពលទៅលើភាពជឿជាក់បាននៃភស្តុតាង"[4]។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានណែនាំថា ដំបូងសហព្រះរាជអាជ្ញាត្រូវដាក់

---

[1] **D193/9** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៤ ដែលពាក់ព័ន្ធទៅនឹងសវនាការនៃសំណុំរឿង០០២/០២, ២៩ មករា ២០១៥។

[2] សំណុំរឿង០០៤-**D193/16** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សំណើជាបន្ទាន់សុំដាក់បង្ហាញឯកសារសម្រាប់សំណុំរឿង០០២ - សំណើ D193/14, ១២ មីនា ២០១៥។

[3] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។

[4] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២, ត្រង់ទំព័រ ១។

សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះ ដោយប្តឹងពីភស្តុតាងដែលខ្លួនចង់ដាក់បង្ហាញ បន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឲ្យទទួលយកឯកសារដែលបានយល់ព្រមនោះសម្រាប់ការដាក់បង្ហាញ[5]។

៤. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានចេញសេចក្តីបង្គាប់ពីមុនថា រាល់ការដាក់បង្ហាញឯកសារទាំងអស់ ពីសំណុំរឿង០០៣ និង០០៤ ចូលទៅក្នុងសំណុំរឿង០០២ គប្បីដាក់ និងជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ដោយចាត់ថ្នាក់បណ្តោះអាសន្នជាប្រភេទឯកសារសម្ងាត់បំផុត ហើយថាអង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចនៅពេលក្រោយ ថាតើគួរត្រូវប្តូរចំណាត់ថ្នាក់ឯកសារទាំងនោះឡើងវិញជាឯកសារសម្ងាត់ដែរ ឬយ៉ាងណា[6]។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា កំណត់ហេតុដែលមាននៅក្នុង **ឧបសម្ព័ន្ធ ញ** ជាប្រភេទឯកសារសម្ងាត់បំផុត។

៥. ការអនុញ្ញាតរបស់ សចអ ឲ្យដាក់បង្ហាញឯកសារ គឺត្រូវស្ថិតនៅក្រោមការកម្រិតនានាដែលមានចែងនៅក្នុងសេចក្តីសម្រេចពីមុនៗរបស់ សចអ និងមានចែងនៅក្នុងសេចក្តីជូនដំណឹងពីមុនៗ ស្តីពីការដាក់បង្ហាញឯកសារ[7]។ ដើម្បីឲ្យត្រូវតាមការកម្រិតទាំងនេះ សហព្រះរាជអាជ្ញានឹងធ្វើឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, មេធាវីការពារក្តី នួន ជា, មេធាវីការពារក្តី ខៀវ សំផន, និងមេធាវីការពារក្តីប្រចាំការរបស់ ខៀវ សំផន អាចទទួលបាននូវសំណៅចម្លងនៃឯកសារដែលមានការដាក់លេខសម្គាល់ទាំងនេះមួយច្បាប់ម្នាក់។

---

[5] **E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងចម្លើយសាក្សីសំណុំរឿង០០៣ និងសំណុំរឿង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង០០២, ១៦ សីហា ២០១៣, កថាខណ្ឌ ២។

[6] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី“ការបង្ហាញចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២”, ២៤ មករា ២០១២, ត្រង់ទំព័រ ១។

[7] *សូមអាន, ឧទា.* **E319.12.1.1** សេចក្តីសម្រេចមួយផ្នែកលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយនៃសំណុំរឿង០០៤ ទាក់ទងនឹងសវនាការលើសំណុំរឿង០០២/០២ និងបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១, ២១ មករា ២០១៥, ត្រង់កថាខណ្ឌ ១៤, ១៥, ១៧, និង ១៨។

## II. ដំណោះស្រាយដែលស្នើសុំ

៦. អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ឲ្យទទួលយកដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវឯកសារ ដែលបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ព័ន្ធ ញ**៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature and stamp] |